**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មការជាតិ សម្រាប់ការអភិវឌ្ឍតាមបែប**
**ប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ**
**លេខាធិការដ្ឋាន (គ.ជ.អ.ប)**

**អង្គភាពត្រួតពិនិត្យ វាយតម្លៃ និងព័ត៌មាន**

ថ្ងៃចន្ទ ១២កើត ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥
រាជធានីភ្នំពេញ, ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២១

**សូមគោរពជូន**

**ឯកឧត្តម ឈួន សំរីទ្ធិ អគ្គនាយកនៃអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

<u>**កម្មវត្ថុ:**</u> សំណើសុំចាត់មន្ត្រីតំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុចូលរួមក្នុងកិច្ចប្រជុំគណៈកម្មការពិនិត្យនិងអនុម័តលទ្ធកម្មកម្រិតទូទៅ(General PRC) ស្តីពីការចរចាកិច្ចសន្យា (Contract Negotiation)នៃគម្រោងសមាហរណកម្មគណនេយ្យភាពសង្គមទៅក្នុងប្រព័ន្ធរដ្ឋបាលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

<u>**យោង:**</u> - កិច្ចព្រមព្រៀងហិរញ្ញប្បទានឥតសំណង Grant Number-TFOB2195 ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០ រវាងរាជរដ្ឋាភិបាលកម្ពុជាជាមួយធនាគារពិភពលោក ស្តីពីការអនុវត្តគម្រោងសមាហរណកម្មគណនេយ្យភាពសង្គមទៅក្នុងប្រព័ន្ធរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។
- សេចក្តីសម្រេច ស្តីពីការបង្កើតគណៈកម្មការពិនិត្យ និងអនុម័តលទ្ធកម្មសម្រាប់គម្រោង សមាហរណកម្មគណនេយ្យភាពសង្គមទៅក្នុងប្រព័ន្ធរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ លេខ ០០៤ ស.ស.រ/ គ.ជ.អ.ប ចុះថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២០។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមមេត្តាជ្រាបថា គម្រោងសមាហរណកម្មគណនេយ្យភាពសង្គមទៅក្នុងប្រព័ន្ធរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិនៃលេខាធិការដ្ឋាន គ.ជ.អ.ប គ្រោងរៀបចំកិច្ចប្រជុំគណៈកម្មការពិនិត្យ និងអនុម័តលទ្ធកម្មកម្រិតទូទៅ (General PRC) ស្តីពីការចរចាកិច្ចសន្យា (Contract Negotiation) ជាមួយបេក្ខជនចំនួន០១រូប ក្នុងមុខតំណែងទីប្រឹក្សាអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន សម្រាប់រយៈពេលខ្លី (Ref. No.: ISAF/NCDDS/IC/04/20) ។

កិច្ចប្រជុំគណៈកម្មការនេះ នឹងប្រព្រឹត្តទៅនៅ**ថ្ងៃអង្គារ៍ ទី២៦ ខែតុលា ឆ្នាំ២០២១ វេលាម៉ោង ៩:៣០នាទីព្រឹក តាមរយៈអនឡាញ**។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមមេត្តាចាត់មន្ត្រីពាក់ព័ន្ធចូលរួមតាមការគួរ។ សូមឯកឧត្តម ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

**ប្រធានគ្រប់គ្រងគម្រោង**

**ម៉ាអុន ម៉ាអូណាត**

ទំនាក់ទំនងលេខ៖ ០១២ ៦៩៩ ៨៩០